រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ០០៩/១៨ ស.ជ.ណ.អ.ជ.ប.គ.ញ.គល

ថ្ងៃពុធ ១រោច ខែភទ្របទ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់ប្រេងឥន្ធនៈ និងប្រេងរំអិល ជូនអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សម្រាប់ប្រើប្រាស់ ក្នុងឆមាសទី២ ឆ្នាំ២០១៨

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សូមជម្រាបជូនដំណឹងដល់បណ្តាក្រុមហ៊ុន (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន ឬសហគ្រាសទាំងអស់បំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានអាស័យដ្ឋានស្ថិតនៅអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (ក្នុងទីស្តីការក្រសួងមហាផ្ទៃ "អគារ ၂") ចាប់ពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ(ទូរស័ព្ទទំនាក់ទំនងលេខៈ ០១២ ៨៨៨ ៧២៦ និង ០៧៧ ២១១ ១១៥)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង១៥:០០នាទីរសៀល ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម (សាលប្រជុំតូច) តាមអាស័យដ្ឋានខាងលើ វេលាម៉ោង១៥:០០នាទីរសៀល ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨។

ក្រុមហ៊ុន ឬសហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន ឬសហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទំនាក់ទំនងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

ឧបនាយករដ្ឋមន្ត្រី
ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
និងជាប្រធាន គ.ល

នាយឧត្តមសេនីយ៍ កែ គឹមយ៉ាន

គ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh